# ខ្លឹមសារសង្ខេបសេចក្តីសម្រេច

***Barrio Altos v. Peru*, IACHR Series C No 75, IHRL 1458 (IACHR 2001), 14 th March 2001**

**<u>ពាក្យគន្លឹះ</u>**៖ ច្បាប់លើកលែងទោស, ការបែងចែកអំណាច, ការទទួលខុសត្រូវរបស់ចៅក្រម (Judge Liability)

**សំណួរ**៖ ច្បាប់លើកលែងទោស ផ្ទុយនឹងសិទ្ធិ ទទួលបានយុត្តិធម៌ដែរទេ?

**១**. ក្នុងឆ្នាំ ១៩៩១ កងកម្លាំងប្រដាប់អាវុធ៦រូប បានឆ្មក់វាយប្រហារសម្លាប់មនុស្សចំនួន ១៥ រូប ដែលកំពុងជប់លៀង ដោយអះអាងថា ពួកទាំងនោះ ជាក្រុមភេរវជន។ គណៈកម្មការព្រឹទ្ធសភា បានបើកធ្វើការស៊ើបអង្កេត តែមិនទាន់បានចប់ទេ (កថា ច) ដោយសារមានរដ្ឋប្រហារ ហើយ លោក Fujimori បានក្លាយជាប្រធានាធិបតីប្រទេសប៉េរូ។ មានការចោទប្រកាន់មនុស្សមួយចំនួន ដោយតុលាការស៊ីវិល តែក្រោយមក តុលាការយោធា បានដណ្តើមយកសំណុំរឿងមកវិនិច្ឆ័យ (កថា ឆ និង ឈ)។ ប៉េរូ បានចេញច្បាប់លើកលែងទោស ដែលមានចែងនូវខ្លឹមសារ មិនអនុញ្ញាតឲ្យមន្ត្រីយោធាទៅចូលរួមផ្តល់សក្ខីកម្ម និងបានលើកលែងទោស ជនដែលត្រូវបានចោទប្រកាន់ពីមុន។ ចៅក្រមបាន ចេញសេចក្តីសម្រេចថា ច្បាប់លើកលែងទោសនេះ មិនត្រូវនឹងរដ្ឋធម្មនុញ្ញទេ៖ *ច្បាប់រដ្ឋធម្មនុញ្ញ ចែងថាចៅក្រមមានកាតព្វកិច្ច មិនអនុវត្តតាមច្បាប់ ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ... មាត្រា ១នៃច្បាប់ លេខ ២៦៤៧៩* (ច្បាប់លើកលែងទោស) *មិនអនុវត្តចំពោះសំណុំរឿងព្រហ្មទណ្ឌនេះទេ.... ដោយសារ ច្បាប់នេះ បានបំពាននូវការធានាដោយច្បាប់រដ្ឋធម្មនុញ្ញ និងកាតព្វកិច្ច ដែលអនុសញ្ញាអាមេរិក ចងកាតព្វកិច្ចដល់ប្រទេស ប៉េរូ។*[1] អង្គជំនុំជម្រះព្រហ្មទណ្ឌ ( Criminal Chamber of Lima Superior Court of Justice) ក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ បានរកឃើញថា ច្បាប់លើកលែងទោស មិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចអន្តរជាតិ ហើយសំណុំរឿងនេះ ត្រូវតែបញ្ចប់។ អង្គជំនុំបានសំអាងថា៖ *ចៅក្រមមិនអាចសម្រេចថាច្បាប់របស់សភាមិនត្រូវអនុវត្តទេ ពីព្រោះ នេះនឹងផ្ទុយនឹងគោលការណ៍នៃការបែងចែកអំណាច*។ ស្របគ្នានេះ អង្គជំនុំជម្រះ បានបញ្ជាឲ្យអង្គភាពត្រួតពិនិត្យផ្ទៃក្នុង ស៊ើបអង្កេតលើចៅក្រម ករណីអំពីបកស្រាយច្បាប់មិនត្រឹមត្រូវនេះ។[2]

**២**. ប៉េរូ បានចេញច្បាប់លើកលែងទោសជាលើកទីពីរ ដោយចែងមិនឲ្យមានការពិចារណាសំណុំរឿងដោយតុលាការ។

---

[1] On June 16, 1995, pursuant to the Constitution of Peru, which indicates that judges have the obligation not to apply those laws that they consider contrary to the provisions of the Constitution, Judge Antonia Saquicuray decided that article 1 of Law No. 26479 was not applicable to the criminal cases pending in her court against the five members of the National Intelligence Service (SIN), since the amnesty violated constitutional guarantees and the international obligations that the American Convention imposed on Peru (para.k).

[2] The judges could not decide that laws adopted by Congress could not be applied, because that would go against the principle of the separation of powers (para.n).

៣. យន្តការសម្របសម្រួលសិទ្ធិមនុស្សជាតិ បានដាក់ពាក្យបណ្ដឹងមកគណៈកម្មការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក ហើយគណៈកម្មការបានបញ្ជូនទៅតុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក (Inter-American Court of Human Rights: IACHR) ដោយអះអាងថា មានការបំពានសិទ្ធិក្នុងមាត្រាទី៤ (សិទ្ធិរស់រានមានជីវិត) មាត្រាទី៥ (សិទ្ធិទទួលបានការប្រព្រឹត្តក្នុងលក្ខណៈមនុស្សធម៌) មាត្រាទី៨ (សិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌) មាត្រាទី២៥ (សិទ្ធិការពារតាមផ្លូវតុលាការ) និងមាត្រាមួយចំនួនទៀត នៃអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស (កថាទី៣៩) ។ បន្ទាប់ពីមានបណ្ដឹង ប្រទេសប៉េរូ បានសម្រេចដកខ្លួនពីយន្តការបណ្ដឹងនេះ។ ក៏ប៉ុន្តែ តុលាការមិនទទួលយក ហើយប្រទេសនេះ ក៏បានទទួលស្គាល់សមត្ថកិច្ចពិនិត្យមើលបណ្ដឹងឡើងវិញ។ ប្រទេសប៉េរូ បានទទួលស្គាល់នូវកំហុសនៃការប្រព្រឹត្តរបស់កងកម្លាំងប្រដាប់អាវុធ ថាបានបំពានសិទ្ធិមនុស្ស និងព្រមទទួលខុសត្រូវ ដោយស្នើឲ្យមានការពន្លឿននីតិវិធី សម្រេចលើសំណងសម្រាប់ជនរងគ្រោះតែម្ដង មិនចាំបាច់ពិនិត្យលើអង្គសេចក្ដីស៊ីជម្រៅទេ។

៤. តុលាការសាទរ ក៏ប៉ុន្តែនៅតែពិនិត្យមើលអង្គសេចក្ដី ដោយរកឃើញថា ប៉េរូ បំពានមាត្រាទី៨ (១) ស្ដីពីសិទ្ធិទទួលបានការពិចារណាក្ដីដោយចៅក្រម, មាត្រាទី ១(១) កាតព្វកិច្ចទទួលបានការការពារដោយច្បាប់ និងដំណោះស្រាយមានប្រសិទ្ធភាព ដោយសារការអនុម័តច្បាប់លើកលែងទោស ដែលបិទផ្លូវមិនឲ្យតុលាការវិនិច្ឆ័យសេចក្ដី។ តុលាការ បានសម្រេចថា ច្បាប់នេះគ្មានសុពលភាពទេ។ ការមិនបានស៊ើបអង្កេត នាំឲ្យមិនបានដឹងអ្វីកើតមានឡើង (សិទ្ធិទទួលបានព័ត៌មាន)។ នេះ ដោយប្រយោល បំពានមាត្រាទី១៣(១) បំពានសិទ្ធិរស់រានមានជីវិត (មាត្រាទី៤) និងសិទ្ធិទទួលបានការប្រព្រឹត្តមនុស្សធម៌ (មាត្រាទី៥)។

<u>**កំណត់សំគាល់**</u>៖ **ក**. ស្រដៀងនឹងយន្តការសិទ្ធិមនុស្សអឺរ៉ុប ដែលមានយន្តការសម្រុះសម្រួល កាត់បន្ថយនូវការពិនិត្យអង្គសេចក្ដីស៊ីជម្រៅ។ ទោះបីជាយ៉ាងនេះក្ដី តុលាការនៅតែពិនិត្យមើល ដែលនេះខុសពីការអនុវត្តកន្លងមកក្នុងសំណុំរឿងស្រដៀងគ្នា។ **ខ**. តុលាការអះអាងថាច្បាប់លើកលែងទោស ផ្ទុយនឹងអនុសញ្ញា និងមិនមានសុពលភាព។ នៅ *អវតក* បញ្ហាផ្លូវច្បាប់នៃការលើកលែងទោស ក៏ត្រូវបានចោទឡើងផងដែរ(*សូមមើល៖ អវតក, អង្គជំនុំជម្រះសាលាដំបូង, សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និង ការលើកលែងទោស និង ការអនុគ្រោះទោស, E51/15, ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១*, សាធារណៈ)។ **គ**. ការបញ្ជាពាក់ព័ន្ធនឹងការបែងចែកអំណាច និងការបកស្រាយច្បាប់ ដែលអាចត្រូវបានចាត់ថាជាការបំពារបំពានអំណាចនៃអង្គកាន់អំណាចមួយ ទៅលើអង្គអំណាចមួយទៀត។ ទោះបីជាយ៉ាងនេះក្ដី តាមយុត្តិសាស្ត្រ ប្រសិនបើការបកស្រាយច្បាប់ វាមិនមែនជាការបំពានការបែងចែកអំណាចទេ ហើយក្នុងករណីគ្មានចេតនាទុច្ចរិត ចៅក្រមនឹងមិនត្រូវបានដាក់ទោសទណ្ឌ ដោយគ្រាន់តែការងារបកស្រាយច្បាប់ទេ។